# វ៉ាក់សាំង COVID-19 សម្រាប់កុមារ

## ប្រការដែលឪពុកម្តាយ/អាណាព្យាបាលគួរដឹង

**វ៉ាក់សាំងជំងឺ COVID-19 មានផ្តល់ជូនមនុស្សអាយុ 6 ខែឡើងទៅ។**

### ហេតុអ្វីកុមារគួរចាក់វ៉ាក់សាំង?

តាំងពីចាប់ផ្តើមមានការឆ្លងជំងឺរាតត្បាតមក កុមារជាង 15 លាននាក់នៅសហរដ្ឋអាមេរិកបានឆ្លងជំងឺ COVID-19។ ការកើនឡើងប្រភេទវីរុសថ្មីនៃជំងឺ COVID-19 យ៉ាងឆាប់រហ័សបានធ្វើឱ្យមានការចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យច្រើនបំផុតក្នុងចំណោមយុវជន។

ពិសោធន៍សាកល្បងវេជ្ជសាស្ត្របានបង្ហាញថា វ៉ាក់សាំងនេះមានប្រសិទ្ធភាពយ៉ាងល្អក្នុងការបង្ការលើជំងឺ COVID-19 ទៅលើយុវជន។ ពួកគេនឹងមានលទ្ធភាពតិចតួចក្នុងការមានជំងឺធ្ងន់ធ្ងរ សម្រាកនៅមន្ទីរពេទ្យ ឬស្លាប់បណ្តាលមកពីជំងឺ COVID-19។

សូមមើល[ការពិភាក្សាអំពីការណែនាំពាក់ព័ន្ធនឹងវ៉ាក់សាំង]នេះ ដើម្បីដឹងពីគន្លឹះទាក់ទងនឹងរបៀបសន្ទនាអំពីវ៉ាក់សាំងជាមួយយុវជន និងគ្រួសារ។

### តើខ្ញុំឲ្យកូនខ្ញុំចាក់វ៉ាក់សាំងដូចម្តេច?

រដ្ឋវ៉ាស៊ីនតោនផ្តល់វ៉ាក់សាំងដែលបានណែនាំទាំងអស់ដោយឥតគិតថ្លៃសម្រាប់កុមារដែលមានអាយុរហូតដល់ 18 ឆ្នាំ។ សួរគ្រូពេទ្យកុមារឬគ្លីនិកជាប្រចាំរបស់កូនអ្នកថាតើពួកគេផ្តល់វ៉ាក់សាំង COVID-19 ដែរឬអត់។

គ្រួសារដែលមិនមានអ្នកផ្តល់សេវាថែទាំសុខភាពអាចទូរសព្ទទៅ **Help Me Grow WA Hotline តាមរយៈលេខ 1-800-322-2588** ឬចូលទៅកាន់ **ParentHelp123.org** ដើម្បីស្វែងរកអ្នកផ្តល់សេវាថែទាំសុខភាព គ្លីនិក ឬធនធានផ្នែកសុខភាពផ្សេងទៀត។ សេវាកម្មនេះពុំមានការគិតថ្លៃទេ ហើយយើងមានផ្តល់ជូនជំនួយផ្នែកភាសា។

អ្នកក៏អាចចូលទៅកាន់ **VaccineLocator.doh.wa.gov** និងប្រើប្រាស់តម្រងដើម្បីមើលតារាងទីកន្លែងនៅក្បែរអ្នកដែលមានវ៉ាក់សាំងសម្រាប់កុមារ។

### តើវ៉ាក់សាំងនេះនឹងជួយដូចម្តេចខ្លះនៅតាមផ្ទះ?

វ៉ាក់សាំង COVID-19 អាចបន្តការពារកុមារពីជំងឺនេះបាន ដែលមានន័យថា ការជួបជុំគ្នាក្នុងអគារកាន់តែមានសុវត្ថិភាពក្នុងការរៀបចំ ឬចូលរួម។ ការចាក់វ៉ាក់សាំងនឹងជួយឱ្យកុមារកាន់តែមានសុវត្ថិភាព និងការពារសមាជិកគ្រួសារនៅក្នុងផ្ទះ។



គ្រួសារគួរតែបន្តអនុវត្តតាមវិធានការសុវត្ថិភាពដែលបានណែនាំផ្សេងទៀតសម្រាប់ការការពារបានល្អបំផុត។

### តើកុមារត្រូវចាក់ប៉ុន្មានដូស?

- កុមារអាយុ **6 ខែដល់ 4 ឆ្នាំ** ចាក់វ៉ាក់សាំងស៊េរី Pfizer ពីរវ៉ាឡង់ដែលមាន 3 ដូស ឬវ៉ាក់សាំងស៊េរី Moderna ពីរវ៉ាឡង់ដែលមាន 2 ដូស។
- កុមារ**អាយុ 5 ឆ្នាំ**ចាក់វ៉ាក់សាំង Pfizer ពីរវ៉ាឡង់ដែលមានតែ 1 ដូស ឬវ៉ាក់សាំងស៊េរី Moderna ពីរវ៉ាឡង់ដែលមាន 2 ដូស។
- កុមារ**អាយុ 6 ឆ្នាំឡើងទៅ** ចាក់វ៉ាក់សាំងពីរវ៉ាឡង់ដែលមានតែ 1 ដូស។

កុមារអាយុ 6 ខែឡើងទៅដែលមានប្រព័ន្ធភាពស៊ាំចុះខ្សោយកម្រិតមធ្យម ឬធ្ងន់ធ្ងរអាចចាក់ដូសពីរវ៉ាឡង់បន្ថែម 1 ដូសយ៉ាងតិច 2 ខែក្រោយពីចាក់ដូសថ្មីចុងក្រោយរួច។

**ដើម្បីទទួលបានចម្លើយសម្រាប់សំណួររបស់អ្នក៖**

**ចូលទៅកាន់៖ VaccinateWA.org/kids**

**ទូរសព្ទទៅ៖ 1-833-VAX-HELP** (1-833-829-4357), **ចុចសញ្ញា #**

មានជំនួយផ្នែកភាសាសម្រាប់ផ្តល់ជូន។

Vaccinate WA

CovidVaccineWA.org

## តើជំងឺ COVID-19 ពិតជាមានហានិភ័យចំពោះកូនរបស់ខ្ញុំមែនទេ?

ទោះបីជាកុមារតិចតួចបានឆ្លងជំងឺ COVID-19 ធៀបទៅនឹងមនុស្សពេញវ័យក៏ដោយ ក៏កុមារអាចៈ

- ឆ្លងវីរុសដែលបណ្តាលឲ្យមានជំងឺ COVID-19
- ធ្លាក់ខ្លួនឈឺ ឬស្លាប់បណ្តាលមកពីជំងឺ COVID-19
- ចម្លង COVID-19 ទៅអ្នកដទៃ
- កើតមានអាការជំងឺធ្ងន់ធ្ងរបណ្តាលមកពី COVID-19 ដូចជា “ជំងឺ COVID រយៈពេលវែង” ឬ ជំងឺរលាកដ៏មានគ្រោះថ្នាក់ ហៅថា MIS-C។

វ៉ាក់សាំងនេះត្រូវបានបង្ហាញថាមានផលរំខានតិចតួចនៅក្នុងចំណោមក្រុមនេះ ហើយវាការពារពួកគេបានយ៉ាងល្អពីជំងឺនេះ។ អត្ថប្រយោជន៍នៃការចាក់វ៉ាក់សាំង គឺមានច្រើនជាងហានិភ័យនៃការកើតជំងឺ COVID-19។

## តើវ៉ាក់សាំងមានសុវត្ថិភាពសម្រាប់កូនខ្ញុំដែរឬទេ?

បាទ/ចាស វ៉ាក់សាំងនេះត្រូវបានចាត់ទុកថាមានសុវត្ថិភាពខ្លាំងសម្រាប់កុមារ។ តាមការពិសោធសាកល្បងវេជ្ជសាស្ត្រលើវ៉ាក់សាំងនេះ គេរកមិនឃើញផលប៉ះពាល់ធ្ងន់ធ្ងរណាមួយចំពោះយុវជនឡើយ។
ការសិក្សាស្រាវជ្រាវកំពុងបន្តអនុវត្ត ហើយសហរដ្ឋអាមេរិកមានប្រព័ន្ធសុវត្ថិភាពវ៉ាក់សាំងយ៉ាងរឹងមាំដើម្បីចាប់សញ្ញាព្រមានណាមួយបានទាន់ពេលវេលា។

## តើផលរំខានទូទៅនៃវ៉ាក់សាំងទៅលើកុមារមានអ្វីខ្លះ?

ហានិភ័យសុខភាពក្នុងករណីកុមារឆ្លងជំងឺ COVID-19 គឺខ្ពស់ខ្លាំងជាងហានិភ័យនៃផលរំខានរបស់វ៉ាក់សាំង។

ដូចគ្នាទៅនឹងវ៉ាក់សាំងផ្សេងទៀតដែរ ផលរំខានទូទៅបំផុតរួមមានការឈឺដៃ អស់កម្លាំង ឈឺក្បាល និងឈឺចុកចាប់សាច់ដុំ។ រោគសញ្ញាទាំងនេះគឺស្រាលជាធម្មតា។

ផលរំខានជាទូទៅមានកម្រិតធ្ងន់ធ្ងរពីស្រាលទៅមធ្យម និងបានកើតមានក្នុងរយៈពេលពីរថ្ងៃក្រោយការចាក់វ៉ាក់សាំង និងភាគច្រើនបាត់ទៅវិញក្នុងរយៈពេលមួយថ្ងៃទៅពីរថ្ងៃ។

## តើកុមារចាំបាច់ត្រូវយកអ្វីខ្លះទៅកាន់ការណាត់ជួប?

ករណីភាគច្រើន ឪពុកម្តាយនិងអាណាព្យាបាលចាំបាច់ត្រូវផ្តល់ការយល់ព្រមទៅលើការចាក់វ៉ាក់សាំងអ្នកដែលមានអាយុក្រោម 18 ឆ្នាំ។ ពួកគេគួរសាកសួរទីតាំងចាក់វ៉ាក់សាំងថាតើពួកគេត្រូវការអ្វីខ្លះដើម្បីទទួលបានការយល់ព្រម។

គ្លីនិកអាចនឹងសួររកប័ណ្ណសម្គាល់ខ្លួនរបស់កុមារ ប័ណ្ណធានារ៉ាប់រង ឬ Social Security number (លេខរបបសន្តិសុខសង្គម) ប៉ុន្តែអ្នកមិនចាំបាច់ផ្តល់ឲ្យពួកគេទេ។

កុមារមិនចាំបាច់ទាល់តែជាពលរដ្ឋអាមេរិក ទើបទទួលបានវ៉ាក់សាំងនោះទេ។ ទីតាំងចាក់វ៉ាក់សាំងមិនអាចសាកសួរអំពីស្ថានភាពអន្តោប្រវេសន៍របស់នរណាម្នាក់នោះទេ។ ទិន្នន័យផ្ទាល់ខ្លួននឹងត្រូវបានប្រើប្រាស់សម្រាប់គោលបំណងសុខភាពសាធារណៈតែប៉ុណ្ណោះ។

## ខ្ញុំមានសំណួរបន្ថែមទៀត។ តើខ្ញុំអាចទៅកន្លែងណា?

ស្វែងរកចម្លើយទៅនឹងសំណួរជាច្រើនទៀតតាមរយៈ **VaccinateWA.org/kids**។ អ្នកក៏អាចពិភាក្សាជាមួយអ្នកផ្តល់ការថែទាំសុខភាពជាប្រចាំរបស់កូនអ្នកផងដែរ។

Washington State Department of HEALTH

**DOH 825-013 April 2022 Khmer**
ដើម្បីស្នើសុំឯកសារនេះជាទម្រង់ផ្សេងទៀត សូមទូរសព្ទទៅលេខ 1-800-525-0127។ អតិថិជនស្តាប់មិនឮ
ឬពិបាកក្នុងការស្តាប់ សូមទូរសព្ទទៅលេខ 711 (Washington Relay) ឬផ្ញើអ៊ីមែលទៅ
civil.rights@doh.wa.gov